# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជានៅព្រះសហគមន៍សន្តយ៉ូសែប
# ផ្សារតូច ថ្ងៃទី១៩ ខែមករា ឆ្នាំ២០២០
# សេចក្តីសុខសាន្តតាមរយៈព្រះរាជ្យរបស់ព្រះជាម្ចាស់

**អត្ថបទទី១៖ អេសាយ ៤៩,៣.៥-៦**

យើងតែងតាំងអ្នកឲ្យធ្វើជាពន្លឺ សម្រាប់បំភ្លឺប្រជាជាតិទាំងឡាយ ហើយនាំការសង្គ្រោះរបស់យើង រហូតដល់ស្រុកដាច់ស្រយាលនៃផែនដី។ អស៤៩,៦

**អត្ថបទទី២៖ កូរិនថូសទី១ ១,១-៣**

ព្រះជាម្ចាស់បានត្រាស់ហៅបងប្អូនឲ្យធ្វើជាប្រជារាស្ត្រដ៏វិសុទ្ធ ព្រមទាំងប្រោសប្រទានឲ្យបានវិសុទ្ធ ក្នុងអង្គព្រះគ្រីស្តយេស៊ូ រួមជាមួយបងប្អូនទាំងអស់ដែលអង្វររកព្រះនាមព្រះយេស៊ូគ្រីស្ត ជាព្រះអម្ចាស់របស់យើងនៅគ្រប់ទីកន្លែង។ ១ករ ១,២

**ដំណឹងល្អ៖ យ៉ូហាន ១,២៩-៣៤**

គឺលោកនេះហើយ ដែលខ្ញុំបានប្រាប់អ្នករាល់គ្នាថា "អ្នកដែលមកក្រោយខ្ញុំ ប្រសើរជាងខ្ញុំ ដ្បិតលោកមានជីវិតមុនខ្ញុំ"។ យហ ១,៣០

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ លោកយ៉ូហានបាទីស្ទគាត់មើលឃើញព្រះយេស៊ូ ហើយគាត់បានប្រកាសដល់មហាជនដែលទទួលពិធីជ្រមុជទឹកថា "**មើលហ្ន៎! លោកនេះហើយជាកូនចៀមរបស់ព្រះជាម្ចាស់ដែលដកបាបចេញពីមនុស្សលោក**"។ ខ្ញុំជឿថា នៅពេលមហាជនបានស្តាប់របៀបដែលលោកយ៉ូហានបាទីស្ទបង្ហាញព្រះយេស៊ូ ប្រហែលគេមិនសូវយល់ប៉ុន្តែបន្តិចម្តងៗ គេបានចាប់ផ្តើមធ្វើដំណើរជាមួយព្រះយេស៊ូ។ ព្រះយេស៊ូ បានចេញពីភូមិណាសារ៉ែតទៅដល់ស្រុកកាលីឡេ បានទទួលពិធីជ្រមុជទឹកនៅពេលនោះមានព្រះសូរសៀងដែលថា "**នេះជាព្រះបុត្រាដ៏ជាទីស្រឡាញ់របស់ខ្ញុំ សូមស្តាប់ព្រះអង្គចុះ**"។ ព្រះយេស៊ូមានព្រះបន្ទូលដំបូងបង្អស់ថា "**ព្រះរាជ្យរបស់ព្រះជាម្ចាស់ជិតមកដល់ហើយ ចូរកែប្រែចិត្តគំនិតហើយជឿលើដំណឹងល្អចុះ**" ដើម្បីឲ្យប្រជាជនចាប់ផ្តើមស្តាប់អំពីជីវិតថ្មីដែលព្រះយេស៊ូចង់ប្រទានឲ្យ។

ព្រះយេស៊ូបានទៅធម្មសាលា ដើម្បីប្រកាសអំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់នៅក្នុងរបៀបថ្មី ណែនាំឲ្យប្រជាជននិងធម្មាចារ្យគេឆ្ងល់ **ហេតុអ្វីពេលព្រះយេស៊ូមានព្រះបន្ទូលពោរពេញដោយអំណាចម្ល៉េះ?** អំណាចមិនមែនមកពីព្រះយេស៊ូពូកែបកស្រាយគម្ពីរ ប៉ុន្តែដោយសារគេឃើញយ៉ាងជាក់ស្តែងព្រះយេស៊ូបានណែនាំឲ្យមនុស្សដែលមានជំងឺជាសះស្បើយ។ ព្រះយេស៊ូបានបន្ត

ធ្វើដំណើរទៅតាមផ្ទះ ដើម្បីឲ្យប្រជាជនមានសេចក្ដីសុខ ព្រះយេស៊ូចាប់ផ្ដើមបើកផ្លូវថ្មីដោយអនុវត្តអំពីការប្រកាសរបស់ព្រះអង្គ "**ព្រះរាជ្យរបស់ព្រះជាម្ចាស់មកជិតបង្កើយហើយ**"។ ពេលយើងនិយាយអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់ ដូចលោកប៉ូលបាននិយាយថា "**សូមព្រះជាម្ចាស់ជាព្រះបិតារបស់យើង និងព្រះអម្ចាស់យេស៊ូគ្រីស្ដប្រណីសន្ដោស និងប្រទានសេចក្ដីសុខសាន្ដដល់បងប្អូន**"។ នេះជាពាក្យជូនពរដែលយើងចង់ស្ដាប់ សូមព្រះជាម្ចាស់ជាព្រះបិតារបស់យើងប្រទានសេចក្ដីសុខសាន្ដដល់បងប្អូន។ ព្រះរាជ្យរបស់ព្រះជាម្ចាស់ ជាស្ថានភាពមួយយ៉ាងពិសេសដែលណែនាំឲ្យមនុស្សយើងទាំងអស់ ទទួលសេចក្ដីសុខសាន្ដមកពីព្រះជាម្ចាស់។

សេចក្ដីត្រូវការរបស់យើង គឺសូមឲ្យមានសេចក្ដីសុខសាន្ដនៅក្នុងជីវិត ជារៀងរាល់ឆ្នាំថ្ងៃទី ០១ ខែមករា យើងគោរពទិវាសន្ដិភាពនៅក្នុងពិភពលោក។ ឆ្នាំនេះ សម្ដេចប៉ាប បានសរសេរលិខិតដែលមានចំណងជើងថា "**សេចក្ដីសុខសាន្ដជាផ្លូវមួយដែលណែនាំឲ្យយើងកែប្រែចិត្តគំនិត ណែនាំឲ្យយើងសម្រុះសម្រួលគ្នាទៅវិញទៅមក ណែនាំឲ្យយើងចេះរួមរស់ជាបងប្អូនគ្នា**"។ នៅក្នុងលិខិតនេះ ប្រហែលយើងអាចសរុបសេចក្ដីដែលយើងទន្ទឹងរង់ចាំនៅក្នុងខ្លួនរបស់យើង គឺសេចក្ដីសុខសាន្ដដែលព្រះយេស៊ូយាងមកប្រកាសតាមរយៈព្រះរាជ្យរបស់ព្រះជាម្ចាស់។

**ទីមួយ** នៅពេលយើងឃើញសេចក្ដីសុខសាន្ដដែលព្រះយេស៊ូចង់ប្រទានឲ្យ យើងត្រូវការយល់ថាព្រះយេស៊ូណែនាំឲ្យយើងរួមរស់នៅក្នុងសង្គមថ្មីប្រកបដោយយុត្តិធម៌ ប្រកបដោយសេចក្ដីស្រឡាញ់ ប្រកបដោយការយល់ចិត្តគ្នា ដើម្បីរកឃើញសេចក្ដីសុខនៅក្នុងខ្លួន។

**ទីពីរ** ព្រះយេស៊ូណែនាំឲ្យយើងចូលនៅក្នុងសង្គមមួយ ដែលចេះសម្រុះសម្រួលគ្នាដើម្បីលើកលែងទោសឲ្យគ្នាទៅវិញទៅមក ដោយសម្រុះសម្រួលផ្ទាល់ខ្លួនជាមួយព្រះជាម្ចាស់សិន។ ការលើកលែងទោស ការប្រណីសន្ដោសរបស់ព្រះជាម្ចាស់ ការសម្រុះសម្រួលគ្នាជាអាទិភាពបំផុត ដើម្បីកសាងព្រះរាជ្យរបស់ព្រះជាម្ចាស់លើផែនដីនេះ។

**ទីបី** យើងរកឃើញអ្វីដែលសំខាន់បំផុត យើងស្វែងរកសុភមង្គលដ៏ពិតប្រាកដ ព្រះយេស៊ូយាងមកដើម្បីឲ្យយើងមានសុភមង្គលដ៏ពេញលក្ខណៈ។

ធម្មទេសនាទីមួយរបស់ព្រះយេស៊ូដល់មហាជននៅលើភ្នំ ព្រះអង្គបានណែនាំឲ្យយើងរួមរស់នៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់ជាប្រចាំថ្ងៃ។ យើងត្រូវតែកែប្រែចិត្តគំនិត ដើម្បីមានចរិតឥរិយាបថថ្មី គឺដាក់ចិត្តជាអ្នកក្រខ្សត់ ជាអ្នកបរិសុទ្ធ និងជាអ្នកសុភាពរាបសា នេះជាឥរិយាបថដែលព្រះយេស៊ូណែនាំឲ្យយើងប្រកាន់ភ្ជាប់ចាប់ពីពេលនេះតទៅ។ បើយើងដាក់ចិត្តជាអ្នកក្រខ្សត់ មានន័យថាយើងលះបង់ចោល ដោយដឹងថាយើងទីពឹងលើព្រះជាម្ចាស់ យើងទីពឹងលើព្រះ

សហគមន៍ យើងទីពឹងលើបងប្អូននៅក្នុងព្រះសហគមន៍ យើងទីពឹងលើព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ពេលយើងលះបង់ចោលជាអ្នកក្រខ្សត់ មានន័យថាយើងដូចកូនក្មេងដែលទីពឹងលើឪពុកម្តាយ យើងទីពឹងលើព្រះបិតាដែលប្រទានសេចក្តីសុខនិងប្រទានព្រះពរឲ្យយើង។ ឲ្យយើងមានសកម្មភាព កុំឲ្យយើងទៅជាគ្រីស្តបរិស័ទអសកម្ម ពេលព្រះយេស៊ូមានព្រះបន្ទូលអ្វីព្រះអង្គអនុវត្តតាមព្រះបន្ទូលនោះ ព្រះយេស៊ូណែនាំឲ្យមនុស្សខ្វះមើលឃើញ អ្នកជាប់ឃុំឃាំងមានសេរីភាព។ ហេតុនេះហើយ គ្រប់ព្រះបន្ទូលរបស់ព្រះយេស៊ូមិនតែជាទស្សនៈ ដែលចេះតែនិយាយដើម្បីឲ្យប្រជាជនស្តាប់ តែជាការអនុវត្តយ៉ាងជាក់ស្តែងនៅក្នុងជីវិតផ្ទាល់របស់ព្រះអង្គ។ ដូច្នេះ យើងក៏ដូចគ្នាដែរ យើងត្រូវតែមានសកម្មភាពជាក់ស្តែង នៅក្នុងផ្លូវនៃសុភមង្គលព្រះយេស៊ូណែនាំឲ្យយើងកសាងសុខសន្តិភាព ឲ្យយើងទៅជាអ្នកដែលបង្ហាញធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ និងឲ្យយើងទៅជាអ្នកស្រេកឃ្លានយុត្តិធម៌។

នៅក្នុងសង្គមយើង យើងធ្វើដូចម្តេចដើម្បីកសាងសុខសន្តិភាព យើងធ្វើដូចម្តេចដើម្បីបង្ហាញធម៌មេត្តាករុណា យើងធ្វើដូចម្តេចដើម្បីណែនាំឲ្យបងប្អូនដែលមានបញ្ហានៅក្នុងជីវិតរកឃើញយុត្តិធម៌ដ៏ពិតប្រាកដ។ នៅក្នុងសារលិខិតរបស់សម្តេចប៉ាប ណែនាំឲ្យយើងមើលឃើញសញ្ញាដ៏តូចតាចដែលមាននៅជុំវិញយើង ណែនាំឲ្យយើងមើលឃើញសាមគ្គីភាព សេចក្តីស្រឡាញ់ដែលណែនាំឲ្យយើងរកឃើញសេចក្តីសុខ។ យើងបានរៀបចំកម្មវិធីសួរសុខទុក្ខអ្នកជាប់ក្នុងមន្ទីរឃុំឃាំង នៅខេត្តតាកែវនិងខេត្តកំពត ជាមួយពុទ្ធសាសនា អ៊ីស្លាមសាសនា និងគ្រីស្តសាសនា។ ពេលយើងអង្គុយនៅមុខមហាជនដែលបានជាប់ក្នុងមន្ទីរឃុំឃាំង យើងឃើញរបៀបនៃសាសនាទាំងអស់ដែលអប់រំ ដែលណែនាំ ដែលលើកទឹកចិត្ត ប្រស់ទឹកព្រះពរ សូត្រធម៌ យើងធ្វើដំណើរជាមួយគ្នានេះជាសញ្ញាសម្គាល់ ដែលយើងធ្វើជាមួយគ្នាដ៏តូចតាចប៉ុន្តែពោរពេញដោយសុភមង្គលសម្រាប់បងប្អូនដែលជាប់នៅទីនោះ។ ប៉ុន្មានថ្ងៃមុន នៅកែបខ្ញុំបានឃើញកូនក្មេងពិការម្នាក់អង្គុយលើរទេះ និងមានកូនពិការម្នាក់ទៀតដែលដើរបានជួយរុញរទេះគាត់ ដើម្បីឲ្យកូនក្មេងពិការដែលជិះលើរទេះបានទៅដល់មាត់សមុទ្រ។ ពេលយើងឃើញរបៀបដែលកូនពិការជួយគ្នា យើងឃើញនេះជាវត្តមានរបស់ព្រះជាម្ចាស់ នេះជាព្រះរាជ្យរបស់ព្រះជាម្ចាស់។ ខ្ញុំជឿថា នៅក្នុងជីវិតផ្ទាល់របស់បងប្អូនអាចនឹកឃើញអំពីសញ្ញាសម្គាល់ នៅពេលយើងកសាងសុខសន្តិភាព នៅពេលយើងចែករំលែកធម៌មេត្តាករុណា នៅពេលយើងណែនាំឲ្យបងប្អូនឯទៀតៗរកឃើញយុត្តិធម៌ នោះណែនាំឲ្យយើងយល់ថាពិតមែនយើងមានសុភមង្គលយ៉ាងពិតប្រាកដ។

ទោះបីយើងកែប្រែឥរិយាបថតាមព្រះយេស៊ូ ទោះបីយើងមានសកម្មភាព យើងត្រូវតែមានឧបសគ្គ យើងត្រូវតែមានឈើឆ្កាង។ ព្រះយេស៊ូមានព្រះបន្ទូលថា "**អ្នកណាដែលយំមានសុភមង្គលហើយ អ្នកណាដែលត្រូវគេបៀតបៀនដោយសារខ្ញុំមានសុភមង្គលហើយ**"។ យើងឆ្លងកាត់ទុក្ខលំបាក យើងឆ្លងកាត់ឧបសគ្គនានាដែលរារាំងផ្លូវនៅពេលយើងប្រកាសដំណឹងល្អ តែកុំឲ្យវាណែនាំឲ្យយើងអស់កម្លាំង ធ្លាក់ទឹកចិត្ត ឬអស់សង្ឃឹមដើម្បីទៅមុខទៀត។ យើងដឹងថា អ្នកណាដែលទទួលការបៀតបៀនអ្នកនោះមានសុភមង្គលហើយ អ្នកណាដែលសោគសៅក៏មានសុភមង្គលដែរ។ ទោះបីមានឧបសគ្គ យើងដឹងថានេះជាឈើឆ្កាងដែលយើងត្រូវតែលីជាមួយព្រះយេស៊ូ ដើម្បីរួមរស់ជាអ្នកកសាងសុខសន្តិភាពរួមជាមួយគ្នា។

យើងអធិដ្ឋានអរព្រះគុណព្រះជាម្ចាស់ យើងទទួលព្រះពរពីព្រះអង្គតាមរយៈលោកប៉ូល "**សូមព្រះជាម្ចាស់ជាព្រះបិតារបស់យើង និងព្រះអម្ចាស់យេស៊ូគ្រីស្ត ប្រណីសន្ដោសនិងប្រទានសេចក្ដីសុខសាន្តដល់បងប្អូន**"។ អាម៉ែន៕